# [illegible]

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# សូត្រមហាកស្សបត្ថេរ ព្រះមហាអានន្ទត្ថេរ
# និងសួរ ឆ្លើយ ព្រះសុត្តន្តបិដក

-នមោតស្ស ភគវតោ អរហតោ្ត សម្មាសម្ពុទ្ធស្ស

-តតោ អាយស្មា មហាកស្សបត្ថេរោ

១.រី ព្រះមហាកស្សបត្ថេរ កាលបើអ្នកដណ្តឹងសួរនូវ ព្រះសុត្តន្តបិដក និងព្រះមហាអានន្ទត្ថេរដូច្នេះហើយ លោកមានថេរវាចាថា: អាវុសោអានន្ទណ្ហើយពេល នេះយើងនឹងសំដែងថ្លែងអំពីទាយក ទាយិកា ដែលបាន ធ្វើបុណ្យទានគ្រប់ជំពូកសព្វថ្ងៃនេះ តែឥលូវនេះយើង នឹងសំដែងអំពីអ្នក ដែលបានរក្សាសីលជាមុនសិន

អើអានន្ទណ្ហើយចុះអ្នកដែលរក្សាសីល៥ តើបានផល្លានិសង្សនោះដូចម្ដេចហើយ ចុះអ្នកដែលបានរក្សាសីល ៨ តើបានផល្លាអានិសង្សនោះដូចម្ដេចដែរ? ចុះចំណែកអ្នកដែលបានរក្សាសីល១០នោះ តើបានផល្លាអានិសង្សនោះយ៉ាងណាខ្លះដែរ? ចូរអ្នកសំដែងថ្លែងឱ្យជាវិត្ថាពិស្ដាមកមើលហ៎ះអ្នកអានន្ទ។

១.អានន្ទោតំសុត្តា រីព្រះមហាអានន្ទត្ថេរកាលបើបានស្ដាប់ថេរវាចាព្រះមហាកស្សបត្ថេរដណ្ដឹងសួរអំពីអានិសង្សបុណ្យដូច្នេះហើយ ពុំយូរឡើយអ្នកក៏មានថេរៈវាចាថា: ភន្តេកស្សបបពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯអ្នកដែលបានរក្សាសីល៥នោះ បានផល្លាអានិសង្ស១០កប្ប ឯអ្នកដែលបានរក្សាសីល៨វិញនោះបានផល្លាអនិសង្ស១២កប្ប ចំណែកអ្នក

ដែលបានព្យាយាមរក្សាសីល១០ នោះបានផលានិសង្ស៣២កប្ប រីឯបុគ្គលឯណាមួយបានដឹងលឺហើយបានខំរក្សាឱ្យបានខ្ជាប់ខ្ជួន បុគ្គលនោះឯងកើតជាតិណាៗនោះនឹងមានរូបឆោមលោមពណ៌នោះល្អស្អាត ហើយមានទ្រព្យសម្បត្តិនោះច្រើន ណាព្រះគុណសូមទ្រង់ជ្រាប ។

២.សាធុៗអាវុសោអានន្ទម្នាលអាវុសោអានន្ទណើ្អយ! កស្សបចូលចិត្តស្តាប់បានហើយ រីចុះអ្នកដែលបានគោរពប្រតិបត្តិថ្វាយបង្គំព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃសព្វៗថ្ងៃនេះតើបានផលានិសង្សនោះដូចម្តេច? ចូរអ្នកសំដែងមកមើលហះអ្នកអានន្ទ ។

២.**ភន្តេកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯបុគ្គលអ្នកដែលបានគោរពប្រតិបត្តិថ្វាយបង្គំចំពោះ

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃសព្វៗថ្ងៃនេះ ហើយក៏បាន
ទឹកគិតដល់ធម៌ទុក្ខនោះនឹងបានផលានិសង្ស១៧កប្ប
មួយទៀតបើគិតដល់ធម៌ អនិច្ចំនោះបានផលានិសង្ស
១៨កប្ប ហើយបានគិតដល់ធម៌អនត្តា ថែមទៀតនឹងបាន
ផលានិសង្ស២០កប្ប ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

៣.សាធុៗអើអានន្ទណ្ហើយកស្សបចូលចិត្តស្តាប់បានហើយ
អានន្ទណ្ហើយចុះ រីឯអ្នកដែលបានបោសជ្រះជម្រះវត្ត
អារាមនោះ តើបានផលានិសង្សនោះដូចម្តេច? ដល់សំ
រេចនឹងស្លាប់ទៅ តើអ្នកនោះនឹងបានទៅកើតទីស្ថាន
ឯណា? ចូរអ្នកសំដែងថ្លែងមកមើលហ៎ះអ្នកអានន្ទ ។
**៣.ភន្តេកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់អើយ
អ្នកដែលបានបោសជ្រះជម្រះវត្តអារាមនោះបានផលា
និសង្ស៥០០កប្ប ដល់ពេលនឹងស្លាប់ទៅបានទៅកើត

ជាទេវបុត្រ លុះច្យុតចុះមកបានទៅកើតក្នុងត្រកូលខ្ពង់ខ្ពស់៥០០ជាតិ ណាព្រះគុណាសូមទ្រង់ជ្រាប ។

៤.សាធុៗអើអានន្ទណ្ហើយ! អ្នកសំដែងមកនេះកស្សបចូលចិត្ត តែខ្ញុំកស្សបនៅសង្ស័យនឹងបុគ្គលដែលបានកសាងព្រះចេតិយ១ ជីកស្រះ ជីកអណ្តូងនេះ១ និងអ្នកដែលបានដាំដើមឈើកេសរផ្កា ថ្វាយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តើបុគ្គលទាំងនោះ បានផលានិសង្សនោះដូចម្តេចដែរ? លុះស្លាប់ទៅ តើបានទៅកើតនៅទីស្ថានឯណាហ្ន៎ះអ្នកអានន្ទ ។

៤.ភន្តេកស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីបុគ្គលដែលបានកសាងព្រះចេតិយនោះបានផលានិសង្ស១ម៉ឺនកប្ប ឯអ្នកដែលបានជីកស្រះ ជីកអណ្តូង និងបានដាំដើមឈើកេសរផ្កា ថ្វាយព្រះពុទ្ធ ព្រះធម៌

ព្រះសង្ឃ រីអ្នកអម្បាលនេះបានផលានិសង្សនោះ៤កប្ប លុះទៅហើយបានទៅកើតជាទេវបុត្រ លុះច្យុតចុះមកបាន កើតជាមហាសេដ្ឋីមានទ្រព្យសម្បត្តិនោះ៨កោដិឃ្លាំង កំណត់បាន ៥០០ជាតិ ណាព្រះគុណសូមទ្រង់ជ្រាប ។

៩.សាធុៗអើរ៉ានន្ទណើ្ហយ! ខ្ញុំកស្សបនៅតែមានមានការ សង្ស័យនឹងមនុស្សលោកសព្វថ្ងៃនេះ ដែលបានកសាង ព្រះពុទ្ធរូបនឹងដីសនោះ តើបានផលានិសង្សប៉ុន្មាន? ចំណែកមួយវិញទៀត ចុះអ្នកបានកសាងនឹងឈើនោះ តើបានផលានិសង្សនោះប៉ុន្មាន ហើយនិងអ្នកដែលបាន កសាងនឹងថ្មសិរិទ្ធ ប្រាក់ សំណ មាស កែវ ស្ពាន់ ផ្កាភ្លុក កុយ ស្នែង តើផលានិសង្សនោះដូចម្តេច? ចូរអ្នកសំដែងថ្លែងរៀបរាប់អោយបានពិស្តាមកមើល ហះអ្នកអានន្ទ ។

៥.ភន្តេកស្សបបពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯ អ្នកដែលបានកសាងព្រះពុទ្ធរូបនឹងដីសនោះ នឹងបាន ផល្លាអានិសង្ស៨កប្ប ឯអ្នកដែលបានកសាង ព្រះពុទ្ធរូបអំពីឈើនោះ បានផល្លាអានិសង្ស ១២កប្ប ចំណែកអ្នកដែលបានកសាងនឹងថ្មនោះបាន ផល្លានិសង្ស១០កប្ប កសាងនឹងសំរិទ្ធនោះបានផល្លា និសង្ស១៧កប្ប និងអ្នកដែលបានកសាងនឹងសំណនោះ បាន ផល្លានិសង្សនោះ១០កប្ប កសាងនឹងប្រាក់នោះបាន ផល្លានិសង្ស៤០កប្ប ចំណែកអ្នកដែលបានកសាងអំពី មាសបានផល្លាអានិសង្ស៦៤កប្ប ឯអ្នកដែលបានកសាង អំពីកែវនោះ បានផល្លានិសង្ស១៧កប្ប ចំណែកមួយវិញ ទៀតអ្នកដែលបានកសាងព្រះរូបអំពីកែវ

ដូចៗគ្នា ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

៦.សាធុៗអើអានន្ទណ្ហើយ! កស្សបចូលចិត្តស្តាប់បាន ហើយ រីចុះអ្នកដែលបានគូរព្រះពុទ្ធនឹងចូឡាមុនី ចេតិយនោះ តើនឹងបានផលានិសង្សនោះដូចម្តេច ដែរ? ចូរអ្នកសំដែងថ្លែងមកមើលហ៎ះអ្នកអានន្ទ ។

៦.**ភន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯ អ្នកដែលបានគូរព្រះពុទ្ធរូបនឹងព្រះចេតិយនោះបាន ផលានិសង្ស២០កប្ប ណាព្រះគុណម្ចាស់សូមទ្រង់ ជ្រាប ។

៧.សាធុៗអើ! អានន្ទកស្សបចូលចិត្តស្តាប់បានហើយ ចុះ អ្នកដែលបានកសាងព្រះពុទ្ធរូបនឹងឈើផ្សេងៗនោះ១ នឹងខ្លឹមច័ន្ទនេះ១ ខ្លឹមអង្កាញ់នេះ១ តើបានផលាអា

និសង្សយ៉ាងណាដែរ ? ចូរអ្នកសំដែងប្រាប់យើងមក មើលហ្ន៎:អ្នកអានន្ទ។

៧.ការឆ្លើយឆ្លង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯអ្នកបានកសាងព្រះពុទ្ធរូបឈើផ្សេងៗនោះ បាន ផលានិសង្ស១២កប្ប ឯអ្នកកសាងនឹងខ្ទឹមប៉ន ខ្ទឹម អង្គាញ់នោះបានផលានិសង្ស១៥កប្ប លុះស្លាប់ ទៅបានកើតទៅជាទេវបុត្រ លុះច្យុតចុះមកបានកើត ជាមហាសេដ្ឋីមានទ្រព្យសម្បត្តិនោះ៨កោដិឃ្លាំង ណា ព្រះគុណម្ចាស់សូមទ្រង់ជ្រាប។

៨.សាធុៗអើអានន្ទណើយ! កស្សបចូលចិត្តណាស់ហើយ រីចុះអ្នកកសាងព្រះពុទ្ធរូបនឹងទង់ដែងនេះ១ នឹងស្ពាន់នេះ១ តើបុគ្គលទាំងពីរជំពូកបានផលានិសង្សនោះដូចម្តេច? ចូអ្នកសំដែងមកមើលហ្ន៎:អ្នក

អានន្ទ !

វ.**ភន្តេកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីអ្នកដែលបានកសាងព្រះពុទ្ធរូបនឹងទង់ដែង រឺនឹងស្ពាន់នោះ ឯអ្នកទាំងពីរជំពូកនោះនឹងបានផលានិសង្ស ១៧កប្បដូចៗគ្នា លុះស្លាប់ទៅបានកើតជាព្រះឥន្ទ្រាធិរាជ៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

៩.សាធុៗ អានន្ទណ្ហើយកស្សបស្តាប់បានហើយ រីចុះអ្នកដែលបានកសាងកុដិសាលា បង្គន់នោះ តើបានផលានិសង្សយ៉ាងណាដែរ? លុះដល់សំរេចនឹងស្លាប់ទៅតើបានកើតនៅទីស្ថានឯណា ចូរអ្នកសំដែងរៀបរាប់មកមើល យើងនឹងចង់ស្តាប់ក្នុងគ្រាឥឡូវនេះណាអ្នកអានន្ទ ។

៩.ភន្តេកស្សបបពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯអ្នកដែលបានកសាងកុដិ សាលា បង្គន់នោះបានផលា

អានិសង្សនោះ៤កប្ប លុះស្លាប់ទៅហើយបានទៅកើត
ជាព្រះឥន្ទ លុះច្យុតចុះមកបានកើតជាមហាសេដ្ឋី មាន
ទ្រព្យសម្បត្តិនោះ៨កោដិឃ្លាំង មានកំណត់៥០០ជាតិ
ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១០.សាធុ ៗអើអានទូណ្ហើយកស្សបចូលចិត្តស្ដាប់បាន
ហើយ ប៉ុន្តែកស្សបនៅមានសង្ស័យនឹងអ្នកដែលបាន
កសាងទូនោះ តើបានផលានិសង្សនោះដូចម្ដេច
ដែរ? ដល់សំរេចនឹងស្លាប់ទៅ តើនឹងបានទៅកើត
នៅទីស្ថានឯណា? ចូរអ្នកសំដែងថ្លែងអោយអស់
ដំណើរសេចក្ដីមកមើល មួយវិញទៀតអ្នកដែលបាន
អោយទានដែកចាននេះ១ បានសង់រោងគាំង
នេះ១ នឹងបានកសាងស្គរសំរាប់ដាក់វត្តអារាមនេះ
១ សង់ស្ពាននេះ១ តើបានផលាអានិសង្សនោះដូច

ម្ដេចដែរ? ចូរអ្នកសំដែងអោយអស់អាថិសេចក្ដី មកមើលហ៎ះអ្នកអានទ្ធ។

១០.**អានន្ទអស្សរ**បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ រីអ្នកដែលកសាងទូនោះ បានផលានិសង្ស៥៥កប្ប លុះស្លាប់ទៅ បានទៅបានកើតជាទេវបុត្រ លុះច្យុត ចុះមកបានកើតជាស្ដេចមហាចក្រមានទ្រព្យសម្បត្តិ នោះ៨ម៉ឺនពាន់ឃ្លាំង ហើយកំណត់៥០០ជាតិ ហើយពុំដែលមានការឃ្លៀងឃ្លាតនិរាសចាកអំពីមាតា បិតា បុត្រ ភិរិយានោះឡើយមានតែសេចក្ដីសុខ រៀងរហូតដល់ព្រះនិព្វាន ចំណែកមួយវិញទៀតបើបាន អោយទានដែកចា ឬសង់រោងរតាំង កសាងស្គរ សំរាប់ដាក់វត្តអារាម ឬក៏បានសង់ស្ពាននោះ បាន ផលានិសង្ស១៦កប្ប លុះស្លាប់ទៅបានទៅកើតជា

ទេវបុត្រ លុះច្យុតចុះមកបានកើតជាមហាសេដ្ឋីមាន

ទ្រព្យសម្បត្តិនោះ៨កោដិឃ្លាំងកំណត់៥០០ជាតិ

ណាព្រះគុណម្ចាស់សូមជ្រាប។

១១.បុ-សាធុៗអើអានន្ទណ្ហើយ! កស្សបចូលចិត្តស្ដាប់បាន

ហើយ អានន្ទណ្ហើយចុះអ្នកដែលបានកសាងផ្លូវថ្នល់

នេះ១ តើបានផលានិសង្សនោះដូម្ដេច? មួយវិញ

អ្នកដែលបានសង់រោងស្មោគ្រាក់ខ្មោរនោះ តើបាន

ផល្លាអានិសង្សនោះដូចម្ដេចដែរ? ចូរអ្នកសំដែងថ្លែង

ប្រាប់យើងមកមើលហ:អ្នកអានន្ទ។

១១.**ទិតន្ទេកស្សប**.បពិត្រព្រះអរិយកស្សបអម្ចាស់

អើយ! វីអ្នកដែលបានកសាងផ្លូវថ្នល់នោះបានផល្លា

អានិសង្ស៥កប្ប លុះស្លាប់ទៅបានកើតជាទេវបុត្រ

លុះច្យុតចុះបានកើតទៅជាស្ដេចមហាចក្រ៥០០ជាតិ

ឯអ្នកដែលបានសង់រោងស្មោគ្រាក់ខ្មោរនោះបាន

ផល្លាអានិសង្ស៤កប្ប លុះស្លាប់ទៅបានទៅកើតជា

ទេវបុត្រ លុះច្យុតចុះមកបានមកកើតជាស្តេចបទេស

រាជ៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

)២.បុ-សាធុៗអើអានន្ទណើ្តយកស្សបចូលចិត្តស្តាប់បាន

ហើយ តែកស្សបចង់សួរអ្នកបន្តទៅទៀតថា: ចុះ

អ្នកដែលបានកសាងគ្រែធម្មាសាន:នេះ១ គ្រែ

សំណើងនេះ១ និងអង្រឹងស្នែង កន្ទេល ពូក ខ្នល់

ខ្នើយ ចៀមចំ ព្រៃព្រំ ស្បែកជើង ផ្តិត ឆ័ត្រ បាត្រ

ឈើច្រត់ វនាំង វាំងនន មុង ភួយ ពិតាន ប្រោស

ស្លឹករិត និងចំលងទូកព្រះសង្ឃបុគ្គលទាំង១៨ជំពូក

នេះ បានផល្លាអានិសង្ស៩កប្ប លុះស្លាប់ទៅបាន

ទៅកើតជាទេវបុត្រ លុះច្យុតចុះមកបានមកកើតជា

មហាសេដ្ឋីមានទ្រព្យសម្បត្តិនោះ៨កោដិឃ្លាំង កំណត់៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១៣.បុ សាធុៗអើអាននុណ្ហើយ កស្សបចូលចិត្តស្តាប់បានហើយ តែចុះអ្នកអោយទានគោ ក្របី ដំរី សេះ រទេះ ទូកក្តា ច្រវ៉ាចែវ ឆ័ត្រ តាំងយូ ក្លោះខ្ចុំ អភិរម្យ ចាហួ មាសមន្ត សែនគ្វាន់ថ្វាយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនោះតើបានផលានិសង្សនោះយ៉ាងណាដែរ? ចូរអ្នកសំដែងថ្លែងរៀបរាប់អោយបានពិស្តារមកមើលហះអ្នកអាននុ ។

១៣.**ទិ_តន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ! វិអ្នកបានថ្វាយគោ ក្របី ដំរី សេះ រទេះ ទូកក្តា ច្រវ៉ាចែវ ឆ័ត្រ តាំងយូ ក្លោះខ្ចុំ អភិរម្យ ចាហួ មាសមន្ត សែនគ្វាន់ថ្វាយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

នោះបានផល្លាអានិសង្ស១០កប្ប លុះស្លាប់ទៅបាន ទៅកើតនៅស្ថានចតុមហារាជិកាន លុះច្យុតចុះមក កាលណាបានកើតជាមហាសេដ្ឋី មានទ្រព្យសម្បត្តិនោះ ៨កោដិឃ្លាំង ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១៤.បុ-សាធុៗ អើអានន្ទណើ្ហយ អ្នកសំដែងមកនេះហៅ សែនពិរោះក្បោះក្បាយញាតិញោមផងទាំងឡាយ សឹងតែចូលចិត្តឥតមានសង្ស័យឡើយ អានន្ទ ណើ្ហយ! ចុះអ្នកដែលបានអោយទាន ស្លាម្លូ ងងូរ ទឹកអំពៅ ថ្នាំ ដីស ក្រដាស ប្រេង ម្សៅ ចេក អំពៅ ត្រាវ ដំឡូង ទាំង១៣ប្រការនេះ តើបានផល្លា និសង្សនោះដូចម្តេចខ្លះ? ហ:អ្នកអានន្ទ ។

**១៤.ទិ-តន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ! រីឯអ្នកដែលបានប្រគេន ស្លាម្លូ ងងូរ ទឹកអំពៅ

ថ្នាំ ជីស ក្រដាស ប្រេង ម្សៅ ចេក អំពៅ ត្រាវ ដំឡូង ទាំង១៣ប្រការនេះបានផលានិសង្ស១០០ កប្ប លុះស្លាប់ទៅបានទៅកើតជាទេវបុត្រ លុះច្យុត ចុះមកបានកើតក្នុងត្រកូលព្រាហ្មណ៍៥០០ជាតិ ណា ព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១៥.បុ-សាធុៗអើអានន្ទណ្ហើយ! កស្សបចូលចិត្តស្តាប់បាន ហើយអានន្ទណ្ហើយកស្សបចង់ដណ្តឹងសួរអំពីដំណើរ បុគ្គលដែលបានធ្វើបុណ្យទានសព្វៗថ្ងៃនេះដែលបាន ដាក់បាត្រព្រះសង្ឃ តើបានផលានិសង្សនោះដូច ម្តេច? ចូរអ្នកសំដែងមកមើល ហៈអ្នកអានន្ទ ។

១៥.**ទិ-អានន្ទកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ រីឯអ្នកដែលបានដាក់បាត្រព្រះសង្ឃសព្វៗថ្ងៃ នេះ បានផលានិសង្សនេះ៣៧កប្ប លុះស្លាប់ទៅ

ហើយបានទៅកើតជាព្រះឥន្ទ្រាធិរាជ លុះច្យុតចុះ មកបានកើតជាស្តេចមហាចក្រ៥០០ជាតិ ណាព្រះ គុណម្ចាស់សូមទ្រង់ជ្រាប ។

១៦.បុ-សាធុៗអើអាននុ្ទណ្ហើយ! កស្សបចូលចិត្តស្តាប់បាន ហើយ អាននុ្ទណ្ហើយចុះអ្នកដែលបានធ្វើបុណ្យក្នុង ថ្ងៃចូលព្រះវស្សានេះ១ ថ្ងៃចេញព្រះវស្សា១ ថ្ងៃចូល បរិវាសកម្មនេះ១ ថ្ងៃចូលឆ្នាំនេះ១ ថ្ងៃភ្ជុំបិណ្ឌនេះ១ ថ្ងៃច្រត់ចង្ក្រាននេះ១ និងអ្នកដែលបានគោរពប្រតិបត្តិ សូត្ររៀនគម្ពីរធម៌អាថិសត្រាបាលីនេះ១ និងអ្នក ភាវនាដើរចង្ក្រមនេះ១ រីឯបុគ្គលទាំង៨ជំពូកនេះ តើបានផលានិសង្សនោះដូចម្តេចខ្លះ? ចូរអ្នកសំដែង ថ្លែងប្រាប់មកមើល ហា:អ្នកអាននុ្ទ ។

១៦.**វិ_អានន្ទ** បពិត្រព្រះអរិយកស្សបអម្ចាស

ហើយ វិបុគ្គលដែលបានធ្វើបុណ្យក្នុងថ្ងៃចូលព្រះវស្សា ឬចេញព្រះវស្សា ថ្ងៃចូលបរិវាសកម្ម ថ្ងៃចូលឆ្នាំ ថ្ងៃភ្ជុំបិណ្ឌ ថ្ងៃច្រត់ចង្ក្រាន និងអ្នកដែលបានគោរពប្រតិបត្តិ សូត្ររៀនគម្ពីធមិអាថិសត្រាបាលី វិបុគ្គលទាំង៨ជំពូកនេះបានផលានិសង្ស១៦កប្បដូច១គ្នា លុះស្លាប់ទៅកើតជាទេវបុត្រ លុះច្យុតចុះមកបានកើតជាស្តេចសាមល្លរាជ៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១៧.បុ.សាធុ១អើ! អានន្ទណ្ហើយ! ចុះអ្នកដែលបានអោយទានសាលាកភត្តនោះ តើបានផលានិសង្សនោះដូចម្តេចដែរ? ហើយនិងអ្នកដែលបានអោយទិចង្ក្រម និងអ្នកអោយទានក្នុងថ្ងៃ៨កើត ៨រោជ ១៥កើត ១៥រោជ ឬថ្ងៃ១៤រោជ នោះក្តី ដល់ព្រះសង្ឃគង់ហត្ថបាស់ក្តី វិបុគ្គលទាំងអម្បាលនោះ តើបានផលា

និសង្សយ៉ាងណាដែរ? ហៈអ្នកអានន្ទ ។

១៧.ថិ.ឆរន្តេកស្សេប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ! រីឯអ្នកដែលបានអោយទានសាលាកភត្ត និងទីចង្ក្រមនោះបានផល្លានិសង្សពោពកប្ប លុះស្លាប់ទៅបានកើតជាទេវតា លុះអស់អានិសង្សកាលណាក៏ច្យុតចុះមកបានកើតជាស្តេចមហាចក្រ៥០០ជាតិ ម្យ៉ាងវិញទៀតអ្នកដែលបានធ្វើទានថ្ងៃ៧កើត ឬ៨រោជ ១៥កើត ១៥រោជ ឬថ្ងៃ១៤រោជនោះក្តីដល់ព្រះសង្ឃគង់ហត្ថបាស់ក្តី រីបុគ្គលទាំងអម្បាលនោះបានផល្លានិសង្ស១៥កប្បដូច១គ្នា ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

១៨.បុ-សាធុ១អើ!អានន្ទរណ្តើយ កស្សបចូលចិត្តស្តាប់បានហើយ ចុះអ្នកដែលបានធ្វើទានក្រៅអំពីថ្ងៃសីលនោះតើបានផល្លានិសង្សនោះដូចម្តេច មួយវិញទៀតចុះអ្នក

ដែលបានធ្វើបុណ្យថ្លុងនោះ តើបានផល្លានិសង្សនោះ ដូចម្ដេច? រីអ្នកទាំងពីរជំពូកនេះ តើបានផល្លានិសង្ស យ៉ាងណាដែរ? ចូរអ្នកសំដែងថ្លែងរៀបរាប់មកមើល ហៈអ្នកអានន្ទ។

១៨.ទិ-ភន្តេកស្សប បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ! រីអ្នកដែលបានធ្វើទានក្រៅអំពីថ្ងៃសីល និង បុគ្គលដែលបានធ្វើបុណ្យថ្លុង រីបុគ្គលទាំងពីរជំពូកនេះបាន ផល្លានិសង្ស១០កប្ប លុះស្លាប់ទៅបានទៅកើតជា ទេវបុត្រ លុះច្យុតចុះមកបានកើតជាមហាសេដ្ឋី៥០០ ជាតិ ណាព្រះគុណសូមទ្រង់ជ្រាប។

១៩.បុ-សាធុៗអើអានន្ទណ្ហើយ! កស្សបចូលចិត្តស្ដាប់បាន ហើយ អានន្ទណ្ហើយចុះអ្នកដែលបានអោយទានដល់ សត្វផងទាំងពួងនេះ១ និងអោយទានដល់អ្នករក្សា

សីល៥ សីល៨ សីល១០ នោះតើបានផល្លានិសង្ស ដូចម្តេច? ចូរអ្នកសំដែងមកមើល ហៈអ្នកអានន្ទ។

១៩.វិ.ភន្តេកស្សបបពិត្រព្រះអរិយកស្សបអម្ចាស់អើយ! វីឯអ្នកដែលបានអោយទានដល់សត្វផងទាំងពួងនោះបាន ផល្លានិសង្ស៤កប្ប ចំណែកអ្នកដែលបានអោយទាន ដល់អ្នករក្សាសីល៥ សីល៨ សីល១០នោះបានផល្លា និសង្ស១៤កប្បដូចៗគ្នា ណាព្រះគុណម្ចាស់សូមទ្រង់ ជ្រាប។

២០.បុ-សាធុៗអើអានន្ទណ្ហើយ! យើងនឹងសួរអ្នកអំពីអា និសង្ស អ្នកដែលបានបំបួសកូនចៅជាសាមណេរនោះ តើបានផល្លានិសង្សដូចម្តេចខ្លះ ចូរអ្នកសំដែងថ្លែង អោយបានពិស្តាមកមើល ហៈអ្នកអានន្ទ។

២០.**វិ.ភន្តេកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់

អើយ រីឯអ្នកបានបំបួសកូនចៅអោយបានសាមណេរ
នោះ បានផល្លានិសង្សនោះ១៦កប្ប លុះស្លាប់ទៅបាន
ទៅកើតនៅនាស្ថានតុសិតមានអាយុនោះ៥០០ឆ្នាំទិព្វ
ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២១.បុ-សាធុៗអើ! អានន្ទណ្ហើយអ្នកឆ្លើយមកនេះ កស្សប
ចូលចិត្តស្តាប់បានហើយ អានន្ទណ្ហើយចុះអ្នកដែលបាន
បំបួសប្តីនោះ តើបានផល្លានិសង្សនោះដូចម្តេច? រួច
ចុះអ្នកបំបួសប្រពន្ធនោះតើបានផល្លានិសង្សនោះ ដូច
ម្តេចដែរ? ចូរអ្នកសំដែងថ្លែងអំពីបុគ្គលទាំងពីរជំពូក
នេះមកមើល ហ៎ះអ្នកអានន្ទ ។

២១.**វិ_ឥន្ទេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់
អើយ រីឯអ្នកដែលបំបួសប្តីឬប្រពន្ធជាសាមណេរនោះបាន
ផល្លានិសង្ស៣០៦កប្ប លុះស្លាប់ទៅហើយបានទៅកើត

នៅស្ថាននិម្មានរតីមានអាយុនោះ១ម៉ឺន៦លានឆ្នាំ មួយវិញទៀត បើបានបំបួសជាភិក្ខុ ភិក្ខុនី ទាំងប្តីប្រពន្ធនោះនឹងបានផលានិសង្ស៦៤កប្ប លុះស្លាប់ទៅកើតនៅស្ថានព្រហ្មលោកជាប្រាកដ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២២.បុ-សាធុៗ អើអានន្ទណ្ហើយ! ដូច្នោះមែនហើយអានន្ទ! ចុះចំណែកអ្នកដែលបានទៅជួយអនុមោទនាគេនោះ តើបានអានិសង្សនោះដូចម្តេច? មួយវិញទៀត ចុះអ្នកដែលបានជួយខ្វល់ខ្វាយជួយសាធុគេនោះ តើបានផលានិសង្សនោះដូចម្តេចដែរ? ហះអ្នកអានន្ទ ។

២២.**ចិ-ភន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីអ្នកដែលបានទៅជួយគេនោះបានផលានិសង្ស

១កប្ប បើបានទៅជួយខ្វល់ខ្វាយជួយសាធុអនុមោទនាគេទៀតនោះនឹងបានផលានិសង្ស១៤កប្ប លុះស្លាប់ទៅកើតជាទេវបុត្រ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៣.បុ-សាធុៗ អាវុសោអានន្ទណើយ! អ្នកឆ្លើយមកនេះពេញសែនពិរោះក្បោះក្បាយហើយទាយកទាយិកាផងទាំងឡាយ ក៏សឹងចូលចិត្តស្តាប់បានហើយ ចុះអ្នកដែលបានបំបួសក្មួយ ឬចៅ និងញាតិមិត្តនោះអោយបានជាសាមណេរក្តី ជាភិក្ខុ ភិក្ខុនីក្តី នឹងបានផលានិសង្សនោះដូចម្តេច? ចូរអ្នកសំដែងថ្លែងរៀបរាប់មកមើលហះអ្នកអានន្ទ ។

២៣.**វិ_ភន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីឯអ្នកដែលបានបំបួសក្មួយជាសាមណេរឬភិក្ខុនោះ បានផលានិសង្ស១២កប្ប លុះស្លាប់ទៅបានទៅ

កើតជាទេវបុត្រនៅស្ថានយាមា មានអាយុនោះ

ពីរពាន់ឆ្នាំទិព្វ បើបានបំបួសចៅជាសាមណេរឬភិក្ខុ

នោះបានផល្លានិសង្ស១៦កប្ប លុះស្លាប់ទៅនឹងបានទៅ

កើតនៅស្ថានសួគ៌ បើបានបំបួសញាតិមិត្តនោះ ទោះជា

សាមណេរក្តី ភិក្ខុក្តីនោះនឹងបានផល្លានិសង្ស១៧កប្ប

លុះស្លាប់ទៅបានទៅសោយសម្បត្តិសុខនៅនាស្ថានសួគ៌

មានអាយុ៥០០ពាន់ឆ្នាំ ថាបើសសើរអំពីអានិសង្ស

អ្នកដែលបានបំបួសនោះវិញសោត សូម្បីតែយកអា

កាសវេហាមកចារស្លឹករិត ឬយកភ្នំព្រះសុមេរុ សិនេរុ

មកធ្វើជាដងកាប៉ាដែកចារ ហើយចារអាកាសវេហា

នោះអោយរិចរិលអស់ទាំងភ្នំព្រះសុមេរុនោះ គង់តែ

កណ្តាលហើយយកទឹកនុប្បមហាសមុទ្រទាំង៤មក

លប់អោយរីងអស់ ហើយអោយមកប្រៀបផ្ទឹមអោយ

ស្មើនឹងកុសលផលបុណ្យនៃអ្នកដែលបានបួសក្នុងព្រះពុទ្ធសាសនា តែមួយភាគនោះក៏ពុំស្មើឡើយ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប។

២៤.បុ-សាធុៗអាវុសោអានន្ទណ្ហើយ! អ្នកឆ្លើយមកនេះត្រូវហើយអានន្ទណ្ហើយ! ចុះអ្នកដែលបានអោយទានភ្លើងក្នុងរដូវរងានោះតើបានផលានិសង្សនោះ ដូចម្តេច? មួយវិញទៀតអ្នកដែលបាននាំផ្កាទៀនផ្កាក្រមួន និងផ្កាក្រដាស ឬនឹងស្មោនោះ តើបានផលានិសង្សនោះដូចម្តេចដែរ? ចូរអ្នកសំដែងមកមើលហះអ្នកអានន្ទ។

**២៤.វិ-តទន្តេភន្តេកស្សបបពិត្រព្រះអរិយកស្សបអម្ចាស់**អើយ រីអ្នកដែលបានអោយទានភ្លើងក្នុងរដូវរងារនោះបានផលានិសង្ស៥កប្ប លុះស្លាប់ទៅបានទៅកើតជាទេវ

បុត្រ លុះច្យុតចុះមកបានកើតជាស្តេចមហាចក្រ ៥០០ជាតិ មួយវិញទៀតអ្នកដែលកសាងផ្កាទៀនផ្កាក្រមួន និងផ្កាក្រដាស ឬនឹងស្មៅនោះបានផលអានិសង្ស៨កប្ប លុះស្លាប់ទៅបានទៅកើតជាទេវបុត្រ លុះច្យុតមកបានទៅកើតជាមហាសេដ្ឋី៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៥.បុ-សាធុៗអើ! អាវុសោអានន្ទណើយចុះអ្នកដែលបានធ្វើបុណ្យមានបាញ់កាំជ្រួចរន្ទាបាញ់កាំភ្លើង មានបង្ហោះបង្ហូតគោមនោះ តើបានផលានិសង្សនោះដូចម្តេច? ចូរអ្នកសំដែងថ្លែងរៀបរាប់អំពីអានិសង្ស នៃបុគ្គលទាំងនោះមកមើល ហៈអ្នកអានន្ទ ។

**២៥.ទំ_ភន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ! រីអ្នកដែលបានធ្វើបុណ្យ ហើយមានអុជកាំជ្រួច

រន្ទានោះបានផល្លានិសង្ស១៥កប្ប វីអ្នកដែលបាញ់កាំភ្លើងនោះបានផល្លានិសង្ស៤កប្ប ចំណែកអ្នកបានធ្វើបុណ្យហើយមានបង្ហោះបង្គួតគោមនោះនិងអុជប្រទីបជ្វាលា ចង្កៀង កែវគោមថ្វាយទេព្តានោះ បានផល្លានិសង្សនោះ១២កប្ប លុះស្លាប់ទៅបានទៅជាទេព្តាមានបរិវារនោះ១ពាន់ៗដូចៗគ្នា ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៦.បុ-សាធុៗអើអានន្ទហើយ កស្សបចូលចិត្តស្តាប់បានហើយអានន្ទណ្ហើយ! កស្សបចង់សួរអ្នកអំពីបុគ្គលដែលបានចារគម្ពីសត្រាដោយខ្លួនឯងក្តីជួលគេអោយចារក្តី តើអ្នកទាំងពីរជំពូកនេះបានផល្លានិសង្សដូចម្តេចដែរ? ចូរអ្នកសំដែងមកមើលហះអានន្ទ ។

**២៦.ទិ_ភន្តេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់

អើយ រីអ្នកដែលបានចារសត្រាដោយខ្លួនឯងក្តី ជូល
អោយគេចារក្តី បានផល្លានិសង្សតែតគណនាត្រារាប់
អោយគ្រប់ពុំអស់ឡើយ លុះស្លាប់ទៅហើយបានទៅ
កើតជាព្រះឥន្ទ្រាធិរាជមានអាយុ៩០០០ឆ្នាំទិព្វ លុះ
ច្យុតចុះមកវិញបានកើតជាស្តេចមហាចក្រ៨ម៉ឺន៤ពាន់
ជាតិ បានកើតជាស្តេចបទេសរាជ៨ម៉ឺន៤ពាន់ជាតិ កើត
ជាស្តេចសាមន្តរាជ៨ម៉ឺន៤ពាន់ជាតិ រួចហើយបានទៅ
កើតនៅស្ថានសួគ៌ទាំង១៦ជាន់ ក្នុងមួយជាន់មាន
៩អសង្ខ័យជាតិណា ព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៧.បុ-សាធុៗអើ!អានន្ទណ្ហើយ កស្សបចូលចិត្តស្តាប់បាន
ហើយអានន្ទណ្ហើយ រីចុះអ្នកដែលបានជូលគេអោយ
លប់សត្រានោះ តើបានផល្លានិសង្សនោះយ៉ាងណា
ដែរ? មួយវិញទៀតចុះបុគ្គលអ្នកយកមាសប្រាក់ជាតិ

អង្គុលទៅបិតសត្រានោះ តើបានផល្លានិសង្សនោះដូចម្តេច? មួយវិញចុះអ្នកដែលអោយស្លឹករិតគេចារនោះតើបានផល្លានិសង្សដូចម្តេច? ចូរអ្នកសំដែងមកកស្សបស្តាប់ផងមើល ហៈអ្នកអានន្ទ ។

២៧.**ទិ-គន្លេ-កស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វិអ្នកដែលបានជួលគេអោយលប់សត្រានោះបានផល្លានិសង្ស៤កប្ប បើបានអោយស្លឹករិតនោះគេចារ ឬអួសបន្ទាត់ដោយត្បូងទឹកឃ្មុំ ឬជ័រទឹកនោះបានផល្លានិសង្ស១កប្ប មួយវិញទៀតបើបានយកទឹកមាស ឬទឹកប្រាក់និងជាតិអង្គុលទៅបិតលំអគម្ពីសត្រានោះបានផល្លានិសង្ស១១កប្ប មួយវិញទៀតបើបានអោយស្លឹករិតទៅចារក្តី នោះបានផល្លានិសង្ស៧កប្ប ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៨.បុ-សាធុៗអើអាននុយើយ! កស្សបចូលចិត្តស្ដាប់បាន ហើយ ចុះអ្នកដែលបានកសាងទង់នឹងសំពត់ថ្មីនោះតើបាន ផលានិសង្សនោះយ៉ាងណាដែរ? ហើយនិងអ្នកបាន កសាងនឹងសំពត់ចាស់នោះ តើបានអានិសង្សដូចម្ដេច ចូរអ្នកសំដែងមកកស្សបស្ដាប់ផងមើល ហះអ្នកអា ននុ។

២៨.**វិ-ភន្តេកស្សប**បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ! រីឯអ្នកដែលបានកសាងទង់នឹងសំពត់ថ្មីនោះបាន ផលានិសង្សនោះ១៨កប្ប ឯអ្នកដែលកសាងនឹងសំពត់ ចាស់នោះបានផលានិសង្ស៥កប្ប មួយវិញទៀតបើទង់ ជាតិនោះបក់កន្ទុយទៅទិសណាៗអ្នកនោះ នឹងបានទៅ កើតជាស្ដេចមហាចក្រនៅទិសនោះឯង ម្យ៉ាងទៀតបើ បុគ្គលឯណាបានកសាងដងទង់នោះនឹងបានផលានិសង្ស

៧កប្ប ហើយបានកើតជាស្តេចមហាចក្រ៥០០ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

២៩.បុ-សាធុៗ អាវុសោអានន្ទណ្ហើយ!កស្សបចូលចិត្ត ស្តាប់បានហើយ! អានន្ទណ្ហើយចុះចំណែកអ្នកដែលបាន ធ្វើបុណ្យពូនភ្នំខ្សាច់នេះ១ ធ្វើបុណ្យបញ្ចុះសីមានេះ១ តើបុគ្គលទាំងពីរជំពូកនេះ តើបានផលានិសង្សនោះ ដូចម្តេចដែរ? ចូរអ្នកសំដែងថ្លែងរៀបរាប់អោយបាន អស់អាថិសេចក្តីមកផងមើល ហ:អ្នកអានន្ទ ។

២៩.**ទិ-គន្ថេកស្សប**បពិត្រព្រះអរិយកស្សប! អម្ចាស់ អើយ រីឯអ្នកដែលបានធ្វើបុណ្យពូនភ្នំខ្សាច់នោះបាន ផលានិសង្ស៣៤កប្ប លុះស្លាប់ទៅបានកើតជាទេវ បុត្រ លុះច្យុតចុះមកបានកើតជាស្តេចមហាចក្រ ៣ម៉ឺន៤ពាន់ជាតិ ណាព្រះគុណម្ចាស់សូមទ្រង់ជ្រាប ។

៣០.បុ-សាធុៗ អើ អានន្ទណ្ហើយ! ត្រូវហើយមហា អានន្ទកស្សបចង់ដឹងបន្តទៀតថា តើអ្នកដែលបានធ្វើ បុណ្យពូនភ្នំខ្សាច់នោះ តើមានទំនៀមទំលាប់នោះអំពី ព្រះពុទ្ធអង្គណា ស្តេចអង្គណា ហើយលោកបានធ្វើអ្វី មកបានជាយើងនាំគ្នាធ្វើតាម ឬមួយក៏ធ្វើតាមតែចិត្ត ឯងនឹកឃើញទេដឹង មួយទៀតធ្វើឡើងរកតែដើម ឈើពោធិព្រឹក្ស បើធ្វើនៅទីវាលឬទីព្រះវិហារ និង ទីចង្រ្កមនោះ តើបានបានផលានិសង្សនោះដូចម្តេច ដែរ? ឬក៏គ្មានទេហៈអ្នកអានន្ទ ។

៣០.**ទិ-គន្ធេកស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ រីឯកិរិយានៃអ្នកដែលបានធ្វើបុណ្យពូនភ្នំខ្សាច់ នោះគឺមានរឿងរ៉ាវមួយដំណាលថាៈ កន្លងរំលងទៅ ហើយនោះមានស្តេចមួយព្រះអង្គព្រះនាម**ព្រះបាទ**

**បទសេនទិកោសលរាជ** ថ្ងៃមួយស្តេចចេញទៅប្រពាតព្រៃនៅប្របឆ្នេរស្ទឹងមួយ ហើយក៏ស្តេចទ្រង់យល់ភ្នកខ្សាច់ ហើយស្តេចក៏បានធ្វើវាទ្បុកចេតិយ លុះស្តេចយាងត្រលប់មកវិញដល់ព្រះនគរហើយ ស្តេចទ្រង់មានវិតក្កៈទ្រង់ក៏ហៅអាមាត្យម្នាក់មកសួរអាមាត្យក៏ក្រាបទូលថាៈ ដូច្នោះមានតែព្រះអង្គយាងទៅទូលសួរព្រះដ៏មានព្រះភាគលុះព្រឹកឡើងព្រះដ៏មានព្រះភាគទ្រង់សំដែងថាៈ <u>បុគ្គលឯណាមួយបានធ្វើវាទ្បុកចេតិយ បើធ្វើនៅទីសាលា នឹងបានកើតក្នុងត្រកូលព្រាហ្មណ៍ បើបានធ្វើនៅទីដើមពោធិព្រឹក្សនឹងបានកើតជាស្តេចក្រុមានអំណាចខ្លាំងក្លា បើធ្វើនៅទីវាល បួចន្លោះនោះក្តី បួមួយក្នុងទីអាវាសស្ថានទីចង្ក្រម អ្នកនោះនឹងបានកើតជាតិណាៗនឹងមានប្រាជ្ញាភ្លឺថ្លាមោះមុតលើសលប់ក្រៃលែងណាព្រះគុណម្ចាស់</u>

បានជាអ្នកផងខំនាំគ្នាធ្វើរឿងរហូតមកដល់សព្វ ថ្ងៃនេះ វីបុណ្យព្ធូនភ្នំខ្សាច់នេះឯង កើតមានទំនៀម ទំលាប់មកអំពីព្រះបាទ **បសេនទិកោសលរាជ** ស្ដេចគង់នៅនគររាជគ្រឹស ណាព្រះគុណម្ចាស់សូម ទ្រង់ជ្រាប ។

៣១.បុ-សាធុៗអើ!អានន្ទណ្ហើយ! យើងបានសំដែងថ្លែង រៀបរាប់អំពីផលានិសង្សបុណ្យក្នុងគម្ពីព្រះសុត្តន្ត បិដកក៏ល្មមសមគួរដល់ញាតិញោមអ្នកស្ដាប់រាល់គ្នា គ្រាន់ជាដំណឹងដឹងតទៅមុខ អយំ សង្ខំបេន មត្តា វីបុច្ឆា នឹងវិសុជ្ជានា អំពីផលានិសង្សបុណ្យក្នុងពេល នេះក៏សន្មតថាចប់ធម៌ទេសនាឥតិបការេនសំរេន ចប់បរិបូណ៌ដោយវេលានេះឯងហោង ។

**ចប់ដោយបរិបូណ៌**

